**អង្គការសហប្រជាជាតិ** A/C.3/57/L.67

**មហាសន្និបាត**

ការចែកចាយមានកំណត់
ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០២
អត្ថបទដើម: អង់គ្លេស

សម័យប្រជុំលើកទី ៥៧
គណៈកម្មាធិការទី ៣
ចំណុចទី ១០៩ (ខ) នៃរបៀបវារៈ
បញ្ហាសិទ្ធិមនុស្ស: បញ្ហាសិទ្ធិមនុស្ស រួមទាំងការដោះស្រាយ
ដើម្បីកែលំអការទទួលបានដោយពិតប្រាកដនូវសិទ្ធិមនុស្ស
និងសេរីភាពជាមូលដ្ឋាន

ប្រទេសអង់គ្លេស អូស្ត្រាលី និងជប៉ុន: សេចក្តីព្រាងសេចក្តីសំរេចចិត្ត

## ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

មហាសន្និបាត

រំលឹកឡើងវិញសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ៥៦/១៦៩ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០១ និងសេចក្តីសំរេចចិត្តលេខ ២០០២/៨៩ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០២[១] របស់គណៈកម្មាធិការសិទ្ធិមនុស្ស និងសេចក្តីសំរេចចិត្តមាន ពាក់ព័ន្ធលើកមុន ៗ ។

ទទួលស្គាល់ថាប្រវត្តិសាស្ត្រប្រកបដោយសោកនាដកម្មនៃប្រទេសកម្ពុជា តម្រូវឱ្យមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្សនៃជនទាំងអស់នៅក្នុងប្រទេសកម្ពុជា និងការមិនវិលត្រឡប់មកវិញនូវនយោបាយ និងការប្រព្រឹត្តនាពេលកន្លងមក ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង

[១] សូមអានការកត់ត្រាជាផ្លូវការរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ឆ្នាំ ២០០២ សេចក្តីបន្ថែមលេខ ៣ (E/2002/23)

ស្ដីពីការ ដោះស្រាយតាមផ្លូវនយោបាយដោយសព្វមុខនៃជម្លោះកម្ពុជា ចុះហត្ថលេខានៅទីក្រុងប៉ារីស នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១[២] ។

បញ្ជាក់ឡើងវិញថា ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជានៅក្នុងប្រវត្តិសាស្ត្រថ្មី ៗ កន្លងទៅនេះ បានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហម និងទទួលស្គាល់ថាការរលំដួលជាចុងក្រោយរបស់ពួកខ្មែរក្រហម និងកិច្ចខិតខំជាបន្តរបស់រដ្ឋាភិបាលកម្ពុជា បានផ្ដល់ជាមូលដ្ឋានចំពោះការរៀបចំឡើងវិញនូវសន្តិភាព និងស្ថេរភាព ក្នុងទិសដៅសំរេចឡើងវិញនូវការបង្រួបបង្រួមជាតិក្នុងប្រទេសកម្ពុជា និងការស៊ើបអង្កេត និងការកាត់ទោសពួកមេដឹកនាំខ្មែរក្រហម ។

I ការគាំទ្ររបស់អង្គការសហប្រជាជាតិ និងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ

១- ស្នើសុំលោកអគ្គលេខាធិការ តាមរយៈតំណាងពិសេសរបស់លោកទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សហការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ជួយរដ្ឋាភិបាលកម្ពុជា ក្នុងការធានាការការពារសិទ្ធិមនុស្ស នៃពលរដ្ឋទាំងអស់ក្នុងប្រទេសកម្ពុជា និងធានាឱ្យមានធនធានសមស្រម ដើម្បីកិច្ចដំណើរការបន្តរបស់ការិយាល័យ និងដើម្បីធ្វើឱ្យតំណាងពិសេសបន្តបំពេញកិច្ចការរបស់លោកប្រកបដោយប្រសិទ្ធិភាព ។

២- ស្វាគមន៍របាយការណ៍របស់លោកអគ្គលេខាធិការ ស្ដីពីតួនាទី និងការសំរេចបានរបស់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស[៣] និងការប្រើប្រាស់មូលនិធិរួមវិភាគទានដោយស្មគ្រចិត្តរបស់អង្គការសហប្រជាជាតិសំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីផ្ដល់ថវិកាដល់កម្មវិធីសកម្មភាពរបស់ការិយាល័យ និងសូមសហគមន៍អន្តរជាតិពិនិត្យការរួមវិភាគទានដល់មូលនិធិនៃការរួមវិភាគទានដោយស្មគ្រចិត្តនេះ ។

៣- ស្វាគមន៍ផងដែររបាយការណ៍របស់តំណាងពិសេស[៤] លើកទឹកចិត្តរដ្ឋាភិបាលឱ្យបន្តកិច្ចសហ

---

[២] (A/46/608-S/23177)

[៣] A/57/277.

[៤] A/57/230.

ប្រតិបត្តិការរបស់ខ្លួន នៅគ្រប់ជាន់ថ្នាក់នៃរដ្ឋាភិបាល គាំទ្រសេចក្តីអំពាវនាវរបស់រដ្ឋាភិបាលកម្ពុជា និងតំណាងពិសេសសូមឱ្យបង្កើនជំនួយអន្តរជាតិដល់ប្រទេសកម្ពុជា និងបន្តធ្វើការឆ្ពោះទៅការកាត់បន្ថយភាពក្រីក្រ និងលើកទឹកចិត្តដល់ប្រទេសផ្តល់ជំនួយ និងភាគីមានពាក់ព័ន្ធដទៃទៀត តាមដានកិច្ចកិច្ចសន្យារបស់ខ្លួនដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ស្តីពីកម្ពុជា ដែលបានប្រព្រឹត្តទៅនៅក្នុងទីក្រុងភ្នំពេញ ពីថ្ងៃទី ១៩ ដល់ ២១ ខែមិថុនា ឆ្នាំ ២០០២ ។

៤- ស្វាគមន៍ថែមទៀតលើការចុះហត្ថលេខា លើអនុស្សរណៈ នៅក្នុងខែកុម្ភៈ ដោយរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការ សំរាប់បន្តអាណត្តិនៃការិយាល័យប្រចាំកម្ពុជា និងលើកទឹកចិត្តរដ្ឋាភិបាលឱ្យបន្តសហប្រតិបត្តិការជាមួយការិយាល័យ ក្នុងកិច្ចខិតខំរួមរបស់ខ្លួនដើម្បីលើកតម្កើងសិទ្ធិមនុស្ស ។

៥- សរសើរដល់តួនាទីជាអាយុជីវិតរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា មានទាំងការអភិវឌ្ឍន៍ផ្នែកសង្គមស៊ីវិលផង និងលើកទឹកចិត្តរដ្ឋាភិបាលកម្ពុជា ឱ្យបន្តធានាដល់ការការពារអង្គការសិទ្ធិមនុស្សទាំងនោះ និងសមាជិករបស់គេ និងបន្តធ្វើការដោយជិតស្និទ្ធ និងដោយសហការជាមួយពួកគេ ។

## II ការកែទម្រង់រដ្ឋបាល ច្បាប់ និងប្រព័ន្ធយុត្តិធម៌

១- ទទួលស្គាល់ការផ្តល់សច្ចាប័នរបស់ប្រទេសកម្ពុជា លើលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិទីក្រុងរ៉ូម[៥] ។

២- កត់សំគាល់ដោយសេចក្តីកង្វល់លើបញ្ហាដែលនៅតែកើតមានជាបន្ត ទាក់ទិនទៅនឹងនីតិរដ្ឋ និងកិច្ចដំណើរការ របស់ប្រព័ន្ធតុលាការ ដែលបណ្តាលមកពី កត្តាផ្សេង ៗដូចជា អំពើពុករលួយ និងការជ្រៀតជ្រែក របស់ផ្នែកនីតិប្រតិបត្តិទៅលើឯករាជភាពរបស់តុលាការ ស្វាគមន៍ការបង្កើតក្រុមប្រឹក្សាកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងជំរុញរដ្ឋាភិបាលឱ្យចាត់ទុកជាបញ្ហាជាអាទិភាព

---

[៥] A/CONF.183/9

ដើម្បីពង្រឹងការផ្តល់ថវិការដល់ តុលាការ និងចាត់វិធានការចាំបាច់ ដើម្បីធានាឯករាជភាព ភាពមិនលំអៀង និងប្រសិទ្ធភាព របស់ឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រម និងប្រព័ន្ធយុត្តិធម៌ទាំងមូល ។

៣- ជំរុញរដ្ឋាភិបាលកម្ពុជា ឱ្យពន្លឿនការអនុម័តច្បាប់ និងក្រមនានា ដែលជាសមាស ភាគសំខាន់នៃក្របខ័ណ្ឌច្បាប់ជាមូលដ្ឋាន រួមមានសេចក្តីព្រាងលក្ខន្តិកៈចៅក្រម ក្រមព្រហ្មទ័ណ្ឌ ក្រមនីតិវិធីក្រមព្រហ្មទ័ណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីថ្មី និងបង្កើនការហ្វឹកហ្វឺនចៅក្រម និងមេធាវី ស្វាគមន៍ការបើកសាលាភូមិន្ទសំរាប់ហ្វឹកហ្វឺនចៅក្រម និងព្រះរាជអាជ្ញា និងមជ្ឈមណ្ឌល ហ្វឹកហ្វឺនមេធាវី និងកែលំអវិជ្ជាជីវៈនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

៤- ជំរុញផងដែរដល់រដ្ឋាភិបាលកម្ពុជា ឱ្យពង្រឹងកិច្ចខិតខំរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាទាក់ ទិននឹងដីធ្លី និងកត់សំគាល់ដោយបារម្ភការចេះតែស្ថិតមានការយកដីដោយបង្ខំ ការបណ្តេញដោយបង្ខំ និងការផ្លាស់ប្តូរទីកន្លែងថ្មីថែមទៀត ។

៥- លើកទឹកចិត្តថែមទៀតដល់កិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តដោយរួសរាន់ និង ដោយពិតប្រាកដកម្មវិធីកែទម្រង់របស់ខ្លួន រួមមានការគ្រប់គ្រងផែនការសកម្មភាព និងការកែទម្រង់កង ទ័ព ដោយមានកម្មវិធីកាត់បន្ថយកងទ័ពផង ។

៦- ស្វាគមន៍ការរីកចំរើនរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីលប់បំបាត់គ្រាប់មីនប្រឆាំងមនុស្ស និង បន្ថយអាវុធធុនស្រាលនៅក្នុងប្រទេសកម្ពុជា និងលើកទឹកចិត្តកិច្ចខិតខំជាបន្ត របស់រដ្ឋាភិបាល និងសហ គមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

៧- សំដែងសេចក្តីកង្វល់យ៉ាងខ្លាំងចំពោះការដែលបញ្ហានិទ័ណ្ឌភាព នៅតែស្ថិតមាននៅកម្ពុជា ទទួលស្គាល់ការចូលពាក់ព័ន្ធ និងកិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ អំពាវ នាវដល់រដ្ឋាភិបាល ឱ្យចាត់ទុកជាអាទិភាពសំខាន់ បង្កើនកិច្ចខិតខំរបស់ខ្លួនដើម្បីស៊ើបអង្កេត និងកាត់ ទោសស្របតាមនីតិវិធីត្រឹមត្រូវនៃច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ចំពោះពួកអ្នកទាំងឡាយណា ទាំងអស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ក្នុងនេះមានការរំលោភសិទ្ធិមនុស្សផង ។

៨- ការស្វាគមន៍ការរីកចំរើនសំរេចបានដោយរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងខែកុម្ភៈ ឆ្នាំ ២០០២ លើកទឹកចិត្តរដ្ឋាភិបាលឱ្យធ្វើការឆ្ពោះទៅការបោះឆ្នោតទូទៅសេរី និងត្រឹមត្រូវ នៅក្នុងខែកក្កដា ឆ្នាំ ២០០៣ ចងចាំជានិច្ចនៅក្នុងអារម្មណ៍សេចក្តីកង្វល់ដ៏ធ្ងន់ធ្ងរចំពោះអំពើបំភិតបំភ័យ អំពើហិង្សា និងការសម្លាប់ និងសេចក្តីរាយការណ៍នានាអំពីការទិញសន្លឹកឆ្នោត សូមឱ្យធ្វើការស៊ើបអង្កេតដោយពេញលេញអំពើបែបនេះ និងកាត់ទោសពួកអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ហាដដែលនេះមិនកើតមានឡើងទៀតទេនៅក្នុងពេលបោះឆ្នោតទូទៅ និងជាពិសេសសូមឱ្យយកចិត្តទុកដាក់ដោយជិតស្និទ្ធទៅលើសុវត្ថិភាព និងសន្តិសុខបេក្ខជន និងសកម្មជននយោបាយ និងធានាអព្យាក្រិតភាពរបស់ស្ថាប័នរដ្ឋ ក្នុងនេះរួមមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឯករាជ្យមួយ ការអនុវត្តន៍ច្បាប់ដោយត្រឹមត្រូវ និងការទទួលបានដោយសមធម៌គ្រប់រូបភាពនៃប្រព័ន្ធឃោសនា រួមមានប្រព័ន្ធផ្សព្វផ្សាយ សំរាប់គណបក្សទាំងអស់ ។

៩- កត់សំគាល់ដោយសេចក្តីកង្វល់យ៉ាងខ្លាំងស្ថានភាពពន្ធនាគារនៃកម្ពុជា កត់សំគាល់ដោយយកចិត្តទុកដាក់កិច្ចខិតខំសំខាន់ខ្លះដើម្បីកែលំអប្រព័ន្ធពន្ធនាគារ សំណូមពរឱ្យមានការបន្តជំនួយអន្តរជាតិដើម្បីកែលំអលក្ខណៈសម្ភារៈនៃការឃុំឃាំង និងអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យចាត់វិធានការបន្ថែមទៀតដើម្បីកែលំអលក្ខណៈឃុំឃាំង ដោយផ្តល់អាហារ និងការថែទាំសុខភាពឱ្យបានត្រឹមត្រូវ ចំពោះអ្នកទោស និងអ្នកជាប់ឃុំ និងបំពេញតម្រូវការជាពិសេសរបស់ស្ត្រី និងកុមារ ។

## III ការរំលោភសិទ្ធិមនុស្ស និងអំពើហិង្សា

១- សំដែងសេចក្តីកង្វល់យ៉ាងធ្ងន់ធ្ងរអំពីការបន្តការរំលោភសិទ្ធិមនុស្ស រួមមានទារុណកម្ម ការឃុំខ្លួនមុនកាត់ទោសហួសកំណត់ ការរំលោភសិទ្ធិការងារ ការបណ្តេញដោយបង្ខំ ក៏ដូចជាហិង្សានយោបាយ ការជាប់ពាក់ព័ន្ធរបស់នគរបាលក្នុងអំពើហិង្សា និងការខ្វះខាតជាជាក់ស្តែងការពារកុំឱ្យមានការសម្លាប់ដោយហ្វូងមនុស្ស កត់សំគាល់ថាមានការរីកចំរើនខ្លះធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាទាំងនេះ និងអំពាវនាវដល់រដ្ឋាភិបាលសូមចាត់វិធានការដ៏ចាំបាច់ទាំងអស់ដើម្បីទប់ស្កាត់អំពើហិង្សាបែប នេះ រួមមានលទ្ធភាពបង្កើតក្រុមប្រឹក្សាស៊ើបអង្កេតមួយស្តីពីបញ្ហាការសម្លាប់ដោយហ្វូងមនុស្ស ។

២- អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ប្រយុទ្ធប្រឆាំងនឹងការរើសអើងក្នុងគ្រប់បាតុភាពទាំងអស់ ប្រឆាំងជនជាតិភាគតិច និងការពារសិទ្ធិរបស់ពួកគេ ក៏ដូចជាបំពេញកាតព្វកិច្ចរបស់ខ្លួនជាភាគីមួយនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងពូជសាសន៍[៦] ដោយមានការស្វែងរកការសុំជំនួយបច្ចេកទេសផង ។

## IV ការការពារស្ត្រី និងកុមារ

១- ស្វាគមន៍ការរីកចំរើនដើម្បីកែលំអឋានៈរបស់ស្ត្រី រួមមានការរីកចំរើនធ្វើឡើងឆ្ពោះទៅឱ្យមានការអនុម័តច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងការការពារអ្នករងគ្រោះនៃអំពើហិង្សា និងអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យចាត់ឱ្យមានឡើងវិធានការសមស្របថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាប្រឆាំងស្ត្រីភេទតាមគ្រប់រូបភាពទាំងអស់ និងចាត់ឱ្យមានវិធានការទាំងអស់ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនជាភាគីមួយ នៃអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងស្ត្រីភេទ[៧] ក្នុងនេះរួមមានទាំងការស្វែងរកជំនួយបច្ចេកទេសផង ។

២- សរសើររដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចខិតខំរបស់ខ្លួនដើម្បីប្រយុទ្ធប្រឆាំង អេចអាយវី/អេដស៍ (HIV/AIDS) ទោះបីជាមានកង្វល់អំពីការកើនឡើងនៃឧប្បត្តិហេតុនេះក៏ដោយ ។

៣- ស្វាគមន៍កិច្ចខិតខំជាច្រើនរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សុំឱ្យរដ្ឋាភិបាល និងសហគមន៍អន្តរជាតិធ្វើការខិតខំរួមគ្នា ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងមូលហេតុរបស់វា និងកត់សំគាល់ដោយមានសេចក្តីបង្វល់យ៉ាងខ្លាំងការកើនឡើងបាតុភូតនៃការជួញដូរមនុស្សចូលនិងអាជីវកម្មផ្លូវភេទ ទៅលើស្ត្រី និងកុមារ ។

៤- ស្វាគមន៍ការផ្តល់សច្ចាប័នដោយរដ្ឋាភិបាលកម្ពុជា ដល់ពិធីសារជ្រើសរើស នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការលក់កុមារ ពេស្យាកម្មកុមារ និងការថតរូបភាពអាសអាភាសរបស់កុមារ[៨] ។

[៦] សេចក្តីសំរេចចិត្ត ២១០៦ A (XX) ឧបសម្ព័ន្ធ

[៧] សេចក្តីសំរេចចិត្តលេខ ៣៤/១៨០ ឧបសម្ព័ន្ធ

[៨] សេចក្តីសំរេចចិត្តលេខ ៥៤/២៦៣ ឧបសម្ព័ន្ធ ៕

៥- កត់សំគាល់ដោយសេចក្ដីកង្វល់យ៉ាងខ្លាំងបញ្ហាការងារកុមារ ក្នុងរូបភាពដ៏អាក្រក់អាក្រីបំផុត អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យចាត់វិធានការជាបន្ទាន់ និងដោយប្រសិទ្ធភាព ដើម្បីការពារកុមារពីអាជីវកម្មសេដ្ឋកិច្ច និងពីការធ្វើការងារដែលមានគ្រោះថ្នាក់ ដែលប៉ះពាល់ការអប់រំរបស់ពួកគេ ឬបំផ្លាញសុខភាព សុវត្ថិភាព ឬផ្លូវចិត្តរបស់ពួកគេ ដោយអនុវត្តច្បាប់កម្ពុជាស្ដីពីការងារកុមារ ច្បាប់ដែលមានស្រាប់ និងបទបញ្ញត្តិច្បាប់សំរាប់កុមារ និងផ្ដន្ទាទោសពួកអ្នករំលោភច្បាប់ទាំងនេះ សូមអង្គការការងារអន្តរជាតិបន្តពង្រីកជំនួយជាចាំបាច់ថែមទៀតក្នុងបញ្ហានេះ និងលើកទឹកចិត្តរដ្ឋាភិបាលសូមពិនិត្យការផ្ដល់សច្ចាប័នអនុសញ្ញាអង្គការងារអន្តរជាតិ ស្ដីពីការហាមឃាត់ និងវិធានការបន្ទាន់សំរាប់លុបបំបាត់រូបភាពអាក្រក់អាក្រីបំផុតនៃការងារកុមារ ( អនុសញ្ញាលេខ ១៨២) ឆ្នាំ ១៩៩៩ ។

៦- លើកទឹកចិត្តកិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីកែលំអថែមទៀតលក្ខណៈសុខភាពរបស់កុមារ និងការទទួលបានការអប់រំរបស់ពួកគេ ជំរុញការចេញសំបុត្រកំណើតដោយសេរីដល់ពួកគេ និងបង្កើតឱ្យមានប្រព័ន្ធយុត្តិធម៌សំរាប់កុមារមួយ ។

V សេចក្ដីសន្និដ្ឋាន

១- លើកទឹកចិត្តសហគមន៍អន្តរជាតិ សូមជួយរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំរបស់ខ្លួន ដើម្បីអនុវត្តន៍សេចក្ដីសំរេចចិត្តនេះ ។

២- សុំលោកអគ្គលេខាធិការរាយការណ៍ជូនមហាសន្និបាត ក្នុងសម័យប្រជុំលើកទី ៥៨ របស់ខ្លួន ស្ដីពីតួនាទី និងការសំរេចបានរបស់ការិយាល័យឧត្តមស្នងការ ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើង និងការការពារសិទ្ធិ និងពីអនុសាសន៍លើកឡើងដោយតំណាងពិសេស ស្ដីពីបញ្ហានានានៅក្នុងអាណត្តិរបស់លោក ។

៣- សំរេចបន្តការពិនិត្យរបស់ខ្លួនអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងសម័យប្រជុំលើកទី ៥៨ របស់ខ្លួន តាមរបៀបវារៈក្រោមចំណងជើងថា " បញ្ហាសិទ្ធមនុស្ស[TH1] " ។

| | |
|---|---|
| Filename: | L.67 K.doc |
| Directory: | P:\COHCHR Documents\2002 & 57th session |
| Template: | C:\Program Files\Microsoft Office\Templates\Normal.dot |
| Title: | GgÁkarshRbCaCati |
| Subject: | |
| Author: | Heng Ham Kheng |
| Keywords: | |
| Comments: | |
| Creation Date: | 01/21/03 9:31 AM |
| Change Number: | 20 |
| Last Saved On: | 05/10/04 2:41 PM |
| Last Saved By: | Touch Huan |
| Total Editing Time: | 52 Minutes |
| Last Printed On: | 05/10/04 2:42 PM |
| As of Last Complete Printing | |
| Number of Pages: | 7 |
| Number of Words: | 1,435 (approx.) |
| Number of Characters: | 8,182 (approx.) |